**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាអាជ្ញាកណ្តាល**
**THE ARBITRATION COUNCIL**

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៨/២០-ឌីកនើធី នីតធើរ & អ៊ីខូ បេស
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង រ៉ូចហ៊ិន**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គីមសិាន**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លៈ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត & ក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី**
អាសយដ្ឋាន ៖ ភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០៦៩ ៥៤ ៨៤ ២៥ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក Liu Wei | អគ្គនាយក |
| ២- លោក ឡៅ ហ៊ិត | រដ្ឋបាល |
| ៣- លោកស្រី ខុន សារ៉េស់ | Compliance |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត & អ៊ីខូ បេស ហ្វេកធើរី**
អាសយដ្ឋាន ៖ ភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០៨៧ ៧៧៧ ៨១៩/០៧០ ៤៦ ៤៦ ៩៦ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក ស៊ាង យ៉ុត | ប្រធានការិយាល័យវិវាទសម្ព័ន្ធសហជីពស៊ីខៅឌូ |
| ២- លោក ភិន សុភា | ប្រធានសហជីព(មូលដ្ឋាន) ប្រចាំក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត |

| | |
|---|---|
| ៣- លោក ចិក ប៊ុនសាន | អនុប្រធានសហជីព(មូលដ្ឋាន)ប្រចាំក្រុមហ៊ុន ឌីកនើជី នីតជើរ លីមីធីត |
| ៤- លោក សេង សឿង | លេខាធិការ(ក្រុមហ៊ុនឌីកនើជី នីតជើរ លីមីធីត) |
| ៥- លោកស្រី ព្រហ្ម ចំរើន | សកម្មជន(ក្រុមហ៊ុន ឌីកនើជី នីតជើរ លីមីធីត) |
| ៦- លោកស្រី យស់ ថាវី | សកម្មជន(ក្រុមហ៊ុន ឌីកនើជី នីតជើរ លីមីធីត) |
| ៧- លោកស្រី សួរ សុជាតិ | សកម្មជន(ក្រុមហ៊ុន ឌីកនើជី នីតជើរ លីមីធីត) |
| ៨- កញ្ញា លន វណ្ណា | សកម្មជន(ក្រុមហ៊ុន ឌីកនើជី នីតជើរ លីមីធីត) |
| ៩- លោកស្រី ហ៊ាង សៅរុន | សកម្មជន(ក្រុមហ៊ុន ឌីកនើជី នីតជើរ លីមីធីត) |
| ១០- លោក ហុង សេងលី | សកម្មជន(ក្រុមហ៊ុន ឌីកនើជី នីតជើរ លីមីធីត) |
| ១១- លោកស្រី យិន ហួច | សកម្មជន(ក្រុមហ៊ុន ឌីកនើជី នីតជើរ លីមីធីត) |
| ១២- លោកស្រី វ៉ាន់ ចាន់ស៊ី | សកម្មជន(ក្រុមហ៊ុន ឌីកនើជី នីតជើរ លីមីធីត) |
| ១៣- លោកស្រី ជឿន ស្រីមុំ | សកម្មជន(ក្រុមហ៊ុន ឌីកនើជី នីតជើរ លីមីធីត) |
| ១៤- លោកស្រី ផាំ ធីម | ប្រធានសហជីព(មូលដ្ឋាន)ប្រចាំក្រុមហ៊ុន អ៊ីខូ បេស ហ្វេកជើរី |
| ១៥- កញ្ញា ឡេង ស្រី | អនុប្រធានសហជីព(មូលដ្ឋាន) ប្រចាំក្រុមហ៊ុន អ៊ីខូ បេស ហ្វេកជើរី |
| ១៦- លោកស្រី សូត ស៊ីណេត | សកម្មជន(ក្រុមហ៊ុន អ៊ីខូ បេស ហ្វេកជើរី) |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលប្រចាំខែធ្នូ ឆ្នាំ២០១៩ លើកទី២ ដែលនៅសល់ជូនកម្មករនិយោជិតទាំងអស់។

២- សូមឱ្យក្រុមហ៊ុនបើកប្រាក់រំលឹកអតីតភាពការងារជូនកម្មករនិយោជិតទាំងអស់តាមពេលវេលាកំណត់។

៣- សូមឱ្យក្រុមហ៊ុនបើកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិតទាំងអស់តាមពេលវេលាកំណត់។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធ

THE ARBITRATION COUNCIL

នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីពីលទ្ធផលនៃការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឌឹកនើជី នីតធើរ លីមីធីត & ក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី លេខ ១០០/២០ ក.ប/កណ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ឌឹកនើជី នីតធើរ លីមីតធីត និងក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន ៣ចំណុច ឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងារនេះទៅតាមនីតិវិធីច្បាប់ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ៣ ចំណុច។ យ៉ាងណាមិញ ភាគីកម្មករនិយោជិតឯកភាពទទួលយកប្រាក់ឈ្នួលសម្រាប់ខែធ្នូ ឆ្នាំ២០១៩ ចំនួន ៥០ ដុល្លារអាមេរិក សិន។ ចំណុចមិនសះជាទាំង ៣ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឌឹកនើជី នីតធើរ លីមីតធីត និងក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី លេខ ១០០/២០ ក.ប/កណ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៧ ខែមករា ឆ្នាំ ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សា នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ២ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាទាំង ៣ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នា។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចទាមទារដែលមិនសះជាចំនួន ៣ចំណុចនេះ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល គឺនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

THE ARBITRATION COUNCIL

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត លេខ MOC ៨២៤៧០៣២៣ ពណ.ចបព ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១។

២- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត លេខ VATL ២០១៧០៨៣៧៩ អពដ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧។

៣- ប័ណ្ណពន្ធប៉ាតង់ក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត លេខ PTL-២០១៩០១៥៨៦៥ អពដ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩។

៤- ប្រកាសបង្កើតរោងចក្រក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត លេខ ៣៩៥.ឧស.កឧ.ប្រក.១២ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨។

៥- បទបញ្ជាផ្ទៃក្នុងនៃក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត ចុះទិដ្ឋាការលេខ ៩៤៧ ក.ប/កណ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៧ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

៦- លក្ខន្តិកៈក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត ចុះទិដ្ឋាការលេខ ២៩១៤/១៦ គ.រ.ក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦។

៧- អនុស្សរណៈនៃការយោគយល់រវាងក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត និងសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា និងសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ឌីកនើធី នីតវើរ លីមីធីត បានចុះបញ្ជីការលេខ ២២៦១/១៥ ក.ប.រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០។

៩- របាយការណ៍ស្តីពីអធិការកិច្ចពិសេសនៅក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត ចុះថ្ងៃ២០ ខែមករា ឆ្នាំ២០២០។

១០- កំណត់ហេតុប្រជុំជាមួយក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០។

១១- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងនិយោជកនៅក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០។

១២- លិខិតដាក់កំហិតលេខ ០០២/២០ ក.ប/កណ ចុះថ្ងៃចន្ទ ១១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ជម្រាបមកលោក/លោកស្រីនាយកក្រុមហ៊ុន ឌីកនើធី នីតវើរ លីមីធីត។

១៣- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនអ៊ិន្ទូ ម៉េសហ្វាក់ធើរី លេខ MOC ២៩៦៥២៥១៣ ពណ.ចបព ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១។

១៤- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី លេខ VATL ២០១៧០៨០៦៥ អពដ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧។

១៥- ប័ណ្ណពន្ធប៉ាតង់ក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី លេខ PTL-២០១៩០១៥៨៦៤ អពដ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩។

១៦- ប្រកាសបង្កើតរោងចក្រក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី លេខ ៨០០.ឧស.កឧ.ប្រក.១២ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។

១៧- បទបញ្ជាផ្ទៃក្នុងនៃក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី ចុះទិដ្ឋាការលេខ ១៨២ ក.ប/កណ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ ដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

១៨- អនុស្សារណៈនៃការយោគយល់រវាងក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី និងសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា និងសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ឌីកនើធី នីតធើរ លីមីធីត បានចុះបញ្ជីកាលេខ ២២៦០/១៥ ក.ប.វ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។

១៩- លក្ខន្តិកៈក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី ចុះទិដ្ឋាការលេខ ២៩១៦/១៦ គ.វ.ក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦។

២០- ឯកសារជាភាសាបរទេស។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចាត់តាំងលោក ស៊ាង យ៉ុត ជាមន្ត្រីដោះស្រាយវិវាទរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ដើម្បីអមសម្របសម្រួលលើករណីដោះស្រាយវិវាទក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត&ក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី លេខ ០០៩/២០ វិវាទ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

២- លិខិតពឹងពាក់ និងប្រគល់សិទ្ធិ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ របស់កម្មករនិយោជិតនៃក្រុមហ៊ុន អ៊ីខូបេស ហ្វេកធើរី សូមពឹងពាក់ និងប្រគល់សិទ្ធិជូនលោក គង់ អាទិត្យ ជាប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ដើម្បីធ្វើជាតំណាងក្នុងការដោះស្រាយវិវាទការងាររួម។

៣- លិខិតពឹងពាក់ និងប្រគល់សិទ្ធិ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ របស់កម្មករនិយោជិតនៃក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត សូមពឹងពាក់ និងប្រគល់សិទ្ធិជូនលោក គង់ អាទិត្យ ជាប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ដើម្បីធ្វើជាតំណាងក្នុងការដោះស្រាយវិវាទការងាររួម។

៤- កំណត់ហេតុប្រជុំជាមួយក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០។

៥- លិខិតលេខ ០០០១/១៨ ក.ប/កណ ចុះថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថា សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី អិល្ធីឌី ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះ តទៅ។

ARBITRATION COUNCIL

៦- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈរបស់សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី លេខ ០០០១/១៨ ក.ប/កណ ចុះថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨។

៧- លិខិតលេខ ០០១៣/១៨ ក.ប/កណ ចុះថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថា សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះ តទៅ។

៨- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈរបស់សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត លេខ ០០១៣/១៨ ក.ប/កណ ចុះថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨។

៩- លិខិតចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ របស់មេធាវី ចាន់ ហឿន សមាជិកការិយាល័យមេធាវីខ្មែរ និងសហការី គោរពជូនលោកប្រធានសហជីព CCAWDU។

១០- លិខិតជូនដំណឹងចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ របស់មេធាវី ចាន់ ហឿន សមាជិកការិយាល័យមេធាវីខ្មែរ និងសហការី គោរពជូនលោកនាយកក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី ស្តីពីការជូនដំណឹងលើកទី២ អំពីការមិនបន្តកិច្ចសន្យាជួលដី (កំណែ) ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១។

១១- លិខិតជូនដំណឹងចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ របស់មេធាវី ចាន់ ហឿន សមាជិកការិយាល័យមេធាវីខ្មែរ និងសហការី គោរពជូនលោកនាយកក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត ស្តីពីការជូនដំណឹងលើកទី២ អំពីការមិនបន្តកិច្ចសន្យាជួលដី (កំណែ) ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១។

១២- កិច្ចសន្យាជួលដី (កំណែ)ក្រុមហ៊ុន ឡាក់គី ហ្វ៊ែរ អ៊ិនធើរប្រាយស៊ីស និងក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១។

១៣- លិខិតប្រកាសពន្ធកាត់ទុកក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៤- វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨១០១១០១ ១០៦៣ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩។

១៥- វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨១០១១០១ ១០៦២ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩។

១៦- កិច្ចសន្យាជួលដី (កំណែ) រវាងក្រុមហ៊ុន ឡាក់គី ហ្វ៊ែរ អ៊ិនធើរប្រាយស៊ីស និងក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១។

១៧- លិខិតប្រកាសពន្ធកាត់ទុកក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

THE ARBITRATION COUNCIL

១៨- វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨១០១១០១ ១០៦៤ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០០៩។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឌីកនើជី នីតធើរ លីមីធីត&ក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី លេខ ១០០/២០ ក.ប/កណ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឌីកនើជី នីតធើរ លីមីធីត & ក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឌីកនើជី នីតធើរ លីមីធីត & ក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី លេខ ០០៣/២០ ក.ប/កណ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ០៣៥ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ០៣៦ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

ក្រុមហ៊ុន ឌីកនើជី នីតធើរ លីមីតធីត និងក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងផ្នែកកាត់ដេរសម្លៀកបំពាក់។ ក្រុមហ៊ុន ឌីកនើជី នីតធើរ លីមីតធីត មានជួលកម្មករនិយោជិតសរុបចំនួន ៨៧៧នាក់ ហើយក្រុមហ៊ុន អ៊ីខូ បេស ហ្វេកធើរី មានជួលកម្មករនិយោជិតសរុបចំនួន ១៧២នាក់ *(យោងតាមអង្គហេតុដែលភាគីទាំងពីរទទួលស្គាល់ក្នុងសវនាការ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០)*។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបើកប្រាក់ឈ្នួលប្រចាំខែធ្នូ ឆ្នាំ២០១៩ ដែលនៅសល់ ជូនកម្មករនិយោជិត**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកប្រាក់ឈ្នួលប្រចាំខែធ្នូ ឆ្នាំ២០១៩ ដែលនៅសល់ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០។
- ភាគីទាំងពីរទទួលស្គាល់ថា៖
    - ជាការអនុវត្តនៅក្នុងក្រុមហ៊ុន និយោជកបើកប្រាក់ឈ្នួលចំនួន ២ដង ក្នុង១ខែ ជូនកម្មករនិយោជិត គឺនៅថ្ងៃទី២២ នៃខែដែលកំពុងធ្វើការ និងនៅថ្ងៃទី៨ នៃខែបន្ទាប់។

- ០ សម្រាប់ប្រាក់ឈ្នួលប្រចាំខែធ្នូ ឆ្នាំ២០១៩ និយោជកបានបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ៥០ដុល្លារអាមេរិក នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩ និង ៥០ ដុល្លារអាមេរិក នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ហើយនិយោជកនៅជំពាក់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតម្នាក់ៗ ចំនួនចន្លោះពី ២០ ដល់ ១០០ ដុល្លារអាមេរិក។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា៖
  - ០ កម្មករនិយោជិតបានបំពេញការងាររបស់ខ្លួនជូននិយោជករួចរាល់ហើយ ប៉ុន្តែ មិនទាន់ទទួលបានប្រាក់ឈ្នួលទេ។
  - ០ យោងតាមមាត្រា ១១៦ នៃច្បាប់ស្តីពីការងារ នៅពេលដែលធ្វើការងារជូននិយោជក កម្មករនិយោជិតត្រូវទទួលបានប្រាក់ឈ្នួល។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា៖
  - ០ ការផ្ទុះឡើងនៃវីរុសកូរ៉ូណាថ្មីនៅប្រទេសចិន ធ្វើឱ្យមានការយឺតយ៉ាវដល់ដំណើរការផ្ទេរប្រាក់មកប្រទេសកម្ពុជា។
  - ០ អ្នកបញ្ជាទិញបានជំពាក់ប្រាក់ និងមិនព្រមសងនិយោជក។
  - ០ មិនមានការបញ្ជាទិញថ្មី ហើយការបញ្ជាទិញខ្លះត្រូវបានផ្អាក។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបើកលើកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិតទាំងអស់ តាមកាលកំណត់**

- ភាគីទាំងពីរទទួលស្គាល់ថា និយោជកបានបើកលើកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី១ ឆ្នាំ២០១៩ ជូនកម្មករនិយោជិតរួចហើយ។
- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកលើកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា យោងតាមប្រកាសលេខ ៤៤៣ និងសេចក្តីណែនាំលេខ ០៤៧ និយោជកមានកាតព្វកិច្ចបើកលើកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ ២០១៩ ជូនកម្មករនិយោជិត។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយផ្អែកតាមមូលហេតុដូចចំណុចវិវាទទី១ ខាងលើដែរ។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបើកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិតទាំងអស់ តាមកាលកំណត់**

- ភាគីទាំងពីរទទួលស្គាល់ថា និយោជកបានប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី១ នៃឆ្នាំ ២០១៩ ជូនកម្មករនិយោជ រួចហើយ។
- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០។
- ភាគីទាំងពីរទទួលស្គាល់ថា ប្រាក់បំណាច់អតីតភាពការងាររបស់កម្មករនិយោជិតនីមួយៗ សម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ មានចំនួនពី ១០០ ដល់ ២០០ ដុល្លារអាមេរិក។

ARBITRATION COUNCIL

- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា យោងតាមប្រកាសលេខ ៤៤៣, សេចក្តីណែនាំ ០៥៧ និង ០៥៨ និយោជកមានកាតព្វកិច្ចបង់ប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិតនៅរៀងរាល់ឆមាស ហើយក្នុងករណីនេះ និយោជកបានជំពាក់ប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ របស់កម្មករនិយោជិត។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយផ្អែកតាមមូលហេតុដូចចំណុចវិវាទទី១ ខាងលើដែរ។

## ហេតុផលនៃសេចក្តីសម្រេច ៖

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបើកប្រាក់ឈ្នួលប្រចាំខែធ្នូ ឆ្នាំ២០១៩ ដែលនៅសល់ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០**

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចបើកប្រាក់ឈ្នួលប្រចាំខែធ្នូ ឆ្នាំ២០១៩ ដែលនៅសល់ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០ ដែរ ឬទេ?

មាត្រា ៦៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ កំណត់និយមន័យនៃកិច្ចសន្យាការងារថា៖ "*១-កិច្ចសន្យាការងារ ត្រូវបានបង្កើតឡើង ដោយការសន្យារបស់ភាគីម្ខាងថា ធ្វើពលកម្មឱ្យភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតសន្យាថា ផ្តល់ប្រាក់ឈ្នួល ទៅលើកិច្ចការពលកម្មនោះ។*

*២-ភាគីដែលបានសន្យាថាធ្វើពលកម្ម ហៅថាកម្មករនិយោជិត ឯភាគីម្ខាងទៀតនោះ ហៅថានិយោជក*"
។

យោងតាមមាត្រា ៦៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅក្នុងកិច្ចសន្យាការងារ កម្មករនិយោជិតត្រូវមានកាតព្វកិច្ចធ្វើពលកម្ម ឬបំពេញការងារជូននិយោជករបស់ខ្លួន ចំណែកឯនិយោជកវិញត្រូវផ្តល់ប្រាក់ឈ្នួល ដែលជាតម្លៃតបស្នងចំពោះកិច្ចការពលកម្ម ដែលកម្មករនិយោជិតនោះបានបំពេញឱ្យនិយោជក។ ក្នុងករណីនេះ ប្រសិនបើកម្មករនិយោជិតមិនបានបំពេញការងារជូននិយោជករបស់ខ្លួននោះទេ នោះនិយោជកក៏មិនមានកាតព្វកិច្ចក្នុងការផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតនោះដែរ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៣៣/១៥- រ៉ូយ៉ាលអេប៊ល សូស អ៊ិនដាស្ទ្រៀល (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី០៣ និងលេខ ០៦៥/១៥-យីបថប ស៊្កតជីង ហ្គូដស៍ (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី២)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងខាងលើដែរ មានន័យថា និយោជកត្រូវផ្តល់ប្រាក់ឈ្នួល ដែលជាតម្លៃតបស្នងចំពោះកិច្ចការពលកម្ម ដែលកម្មករនិយោជិតនោះបានបំពេញឱ្យនិយោជក។

យោងតាមអង្គហេតុខាងលើ ភាគីទាំងពីរទទួលស្គាល់ថា កម្មករនិយោជិតបានបម្រើការងារសម្រាប់ខែធ្នូជូននិយោជករួចហើយ។ រីឯនិយោជកបានបើកប្រាក់ឈ្នួលសម្រាប់ខែធ្នូ ឆ្នាំ២០១៩ ជូនកម្មករនិយោជិត ចំនួន ៥០ ដុល្លារអាមេរិក នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩ និងចំនួន ៥០ ដុល្លារអាមេរិក នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ហើយនិយោជកមិនទាន់បើកប្រាក់ឈ្នួលដែលនៅសល់ទៀតសម្រាប់ខែធ្នូ ឆ្នាំ២០១៩ ជូនកម្មករនិយោជិតទេ។ ករណីនេះ និយោជកបានលើកឡើងថា និយោជកពុំមានលទ្ធភាព ដើម្បីផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតទេ ដោយលើកហេតុផលពីបញ្ហាវីរុសកូរ៉ូណាថ្មីដែលធ្វើឱ្យរាំងស្ទះដល់ដំណើរការផ្ទេរប្រាក់ និងអ្នកបញ្ជាទិញជំពាក់ប្រាក់និយោជក និងមានការផ្អាកការបញ្ជាទិញ។ បើទោះជានិយោជកគ្មានប្រាក់ និយោជកនៅតែមានកាតព្វកិច្ច

ARBITRATION COUNCIL

ក្នុងការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ដែលជាតម្លៃតបស្នងនឹងកិច្ចការពលកម្មដែលកម្មករនិយោជិតបានបំពេញជូននិយោជក។

បន្ថែមពីនេះ ប្រការ១ នៃប្រកាសលេខ ៤៤២ ក.ប.ប្រ.ក.ខ.ល ស្តីពីការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ចែងថា៖ *"ចាប់ពីខែមករា ឆ្នាំ២០១៩ តទៅ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវរៀបចំឱ្យមានការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ចំនួន ២(ពីរ)ដង ក្នុងមួយខែ ដោយត្រូវបើកលើកទី១ ក្នុងសប្តាហ៍ទី២(ពីរ) និងលើកទី២ ក្នុងសប្តាហ៍ទី៤(បួន) នៃខែនីមួយៗ តាមបែបបទដូចខាងក្រោម៖*

- *លើកទី១ គឺស្មើនឹងចំនួន ៥០% (ហាសិបភាគរយ) នៃប្រាក់ឈ្នួលសុទ្ធសាធក្នុង ១(មួយ)ខែ*
- *លើកទី២ គឺស្មើនឹងចំនួនប្រាក់ឈ្នួលសុទ្ធសាធដែលនៅសល់ ប្រាក់ឈ្នួលបន្ទាប់បន្សំ និងអត្ថប្រយោជន៍ផ្សេងៗទៀត ដែលកម្មករនិយោជិតត្រូវទទួលបាននៅក្នុងខែនីមួយៗ។"*

យោងតាមខ្លឹមសារនៃមាត្រា ១១៦ នៃច្បាប់ស្តីពីការងារ និងប្រការ១ នៃប្រកាសលេខ ៤៤២ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចបើកប្រាក់ឈ្នួលចំនួនពីរដង ក្នុងមួយខែ ជូនកម្មករនិយោជិត។ ការបើកប្រាក់ឈ្នួលលើកទី១ នៅសប្តាហ៍ទី២ និងលើកទី២ នៅសប្តាហ៍ទី៤ នៃខែនីមួយៗ ដោយខានពុំបាន។ *(សូមមើលសេចក្តីបង្គាប់លេខ ០៨៥/១៩-ជិន យី ហ្គាមេន (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី៤)*

យោងតាមប្រកាសខាងលើ និយោជកត្រូវបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន ២ដង ក្នុងមួយខែ។ ករណីនេះ និយោជកបានបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ២ដង ក្នុងមួយខែ រួចហើយ ប៉ុន្តែ និយោជកបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតមិនទាន់គ្រប់ចំនួន។ យោងតាមខ្លឹមសារនៃប្រកាសខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានបញ្ញត្តិណាមួយអនុញ្ញាតឱ្យនិយោជកពន្យារការបើកប្រាក់ឈ្នួកជូនកម្មករនិយោជិតឡើយ។ ប៉ុន្តែ ក្នុងករណីនេះ និយោជកបានខកខានក្នុងការបំពេញកាតព្វកិច្ចតាមបញ្ញត្តិនៃប្រកាសនេះ បើទោះបីជាកម្មករនិយោជិតបានជួយសម្រាលបន្ទុកនិយោជក និង យល់ព្រមពន្យារពេលបើកប្រាក់ឈ្នួលទៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០ ក៏ដោយ ពោលគឺមានរយៈពេល ១ខែ ក្រោយថ្ងៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលកំណត់ដោយប្រកាសខាងលើ។

សរុបសេចក្តីមក ផ្អែកតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មិនមានច្បាប់ ឬបទប្បញ្ញត្តិទាក់ទងនឹងវិស័យការងារណាមួយ ដែលអនុញ្ញាតឱ្យនិយោជកពន្យារការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតឡើយ។

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកប្រាក់ឈ្នួលប្រចាំខែធ្នូ ឆ្នាំ២០១៩ ដែលនៅសល់ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០។ យ៉ាងណាមិញ កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់នេះ គឺនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកបើកប្រាក់ឈ្នួលសម្រាប់ខែធ្នូ ឆ្នាំ២០១៩ ដែលនៅសល់ ជូនកម្មករនិយោជិត នៅថ្ងៃដែលសេចក្តីបង្គាប់អាជ្ញាកណ្តាលនេះ ចូលជាស្ថាពរ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបើកប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារ សម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០**

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបើកលើកប្រាក់

ARBITRATION COUNCIL

បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០ ដែរ ឬទេ?

មាត្រា ៨៩ (ថ្មី) នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ៨៧ ចំណងជើងចំណុច "គ" ផ្នែកទី៣ នៃជំពូកទី៤ មាត្រា ៨៩ មាត្រា ៩០ មាត្រា ៩១ មាត្រា ១១០ មាត្រា ១២០ មាត្រា ១២២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ (តទៅនេះហៅថា មាត្រា ៨៩ថ្មី នៃច្បាប់ស្តីពីការងារ) ចែងថា៖ "*និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតដែលកំពុងបម្រើការងារនូវប្រាក់បំណាច់អតីតភាពការងារដែលស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន ១៥ (ដប់ប្រាំ)ថ្ងៃ ក្នុង១(មួយ)ឆ្នាំ។ រៀងរាល់ ៦(ប្រាំមួយ)ខែ និយោជកត្រូវទូទាត់ជូនកម្មករនិយោជិតនូវប្រាក់បំណាច់អតីតភាពការងារនេះ ចំនួនពាក់កណ្តាល...*

*វិសាលភាព និងបែបបទនៃការអនុវត្តប្រាក់បំណាច់អតីតភាពការងារនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ*"។

យោងតាមខ្លឹមសារកថាខណ្ឌទី៤ នៃមាត្រា ៨៩ថ្មី ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ០៧១/១៩-អេ អិម ៣ (ខេមបូឌា) ហ្គាមេនបកស្រាយថា៖ "វិសាលភាពអនុវត្ត និងបែបបទនៃការអនុវត្តផ្តល់ប្រាក់បំណាច់អតីតភាពការងារចំនួន ១៥ថ្ងៃ ក្នុងមួយឆ្នាំ ដោយនិយោជកត្រូវទូទាត់ចំនួន ២ដង ក្នុងមួយឆ្នាំជូនកម្មករនិយោជិត គឺត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។ រីឯការគណនា និងការទូទាត់អតីតភាពការងាររបស់កម្មករនិយោជិតដែលមានមុនច្បាប់នេះចូលជាធរមាន (មានមុនមាត្រា ៨៩ថ្មី ចូលជាធរមាន) គឺត្រូវអនុវត្តតាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារផងដែរ"។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ មានន័យថា និយោជកត្រូវទូទាត់ប្រាក់បំណាច់អតីតភាពការងារចំនួន ១៥ថ្ងៃ ក្នុងមួយឆ្នាំ ជូនកម្មករនិយោជិត ចំនួន ២ដង ក្នុងមួយឆ្នាំ ផ្អែកតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

ប្រការ ៣ នៃប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ចែងថា៖ "*ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ របស់កម្មករនិយោជិត ដែលបាននិងកំពុងបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន ត្រូវអនុវត្តតាមបែបបទដូចខាងក្រោម៖*

*១-ចំពោះសហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និយោជកត្រូវបើករំលឹកចំនួន ៣០(សាមសិប)ថ្ងៃ នៃប្រាក់បំណាច់អតីតភាពការងារសរុប រៀងរាល់១(មួយ)ឆ្នាំម្តង ដោយ៖*

- *ចំនួន១៥ (ដប់ប្រាំ)ថ្ងៃ នៅក្នុងខែមិថុនា នៃឆ្នាំនីមួយៗ និង*
- *ចំនួន១៥ (ដប់ប្រាំ)ថ្ងៃ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ...*"។

ចំណុចទី៣ នៃសេចក្តីណែនាំ ០៥៧ ក.ប/ស.ណ.ន.ខ.ល ស្តីពីការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ សម្រាប់សហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ចែងថា៖ "*និយោជកត្រូវបើករំលឹកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិត ២ដង ក្នុង១ឆ្នាំ ដែលក្នុងម្តងៗស្មើនឹងប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមចំនួន ១៥ថ្ងៃ គឺចំនួន ១៥ថ្ងៃ នៅពេលបើកប្រាក់ឈ្នួលលើកទី២ សម្រាប់ខែមិថុនា និងចំនួន ១៥ថ្ងៃទៀត នៅពេលបើកប្រាក់ឈ្នួលលើកទី២*

THE ARBITRATION COUNCIL

*សម្រាប់ខែធ្នូ នៃឆ្នាំនីមួយៗ។ ការបើករំលឹកនេះ និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតទៅតាមអតីតភាពការងារជាក់ស្តែងរបស់កម្មករនិយោជិតម្នាក់ៗ ពោលគឺចាប់ផ្តើមពីឆ្នាំ២០០៨ រៀងមក"*។

យោងតាមប្រការ ៣ នៃប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ និង ចំណុចទី៣ នៃសេចក្តីណែនាំ ០៥៧ ក.ប/ស.ណ.ន.ខ.ល ស្តីពីការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ សម្រាប់សហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចបើករំលឹកប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ ជូនកម្មករនិយោ-ជិត។ នៅក្នុងសំណុំរឿងនេះ និយោជកបានបើករំលឹកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី១ ឆ្នាំ២០១៩ ជូនកម្មករនិយោជិតរួចហើយ ប៉ុន្តែ និយោជកពុំបានបើករំលឹកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិត សម្រាប់ឆមាសទី២ ឬខែធ្នូ ឆ្នាំ២០១៩ នោះទេ ដោយលើកហេតុផលអំពីមូលហេតុនៃការផ្ទុះឡើងនៃវីរុសកូរ៉ូណា ហើយអ្នកបញ្ជាទិញជំពាក់ប្រាក់ និងផ្អាកការបញ្ជាទិញ។

ពាក់ព័ន្ធនឹងការលើឡើងរបស់និយោជកនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មិនមានបញ្ញត្តិណាមួយនៃច្បាប់និងប្រកាសទាក់ទងនឹងវិស័យការងារអនុញ្ញាតឱ្យនិយោជកពន្យារពេលបើករំលឹកប្រាក់បំណាច់អតីតភាពជូនកម្មករនិយោជិតឡើយ។

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០។ យ៉ាងណាមិញ កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់នេះ គឺនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកបើកប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិតនៅថ្ងៃដែលសេចក្តីបង្គាប់អាជ្ញាកណ្តាលនេះ ចូលជាស្ថាពរ។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកជកបើកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០**

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបើកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០ ដែរឬទេ?

សូមមើលការបកប្រាយមាត្រា ៨៩ថ្មី នៃច្បាប់ស្តីពីការងារ អំពីប្រាក់បំណាច់អតីតភាពការងារ នៅក្នុងចំណុចវិវាទទី២ ខាងលើ។

ប្រការ ២ នៃប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ដដែល ចែងថា៖ *"ការផ្តល់ប្រាក់បំណាច់អតីតភាពការងារ២(ពីរ)ដង ក្នុងមួយឆ្នាំ ត្រូវអនុវត្តចាប់ពីឆ្នាំ២០១៩ តទៅ ស្របតាមបែបបទដូចខាងក្រោម៖*

*១-និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតដែលកំពុងបម្រើការងារ នូវប្រាក់បំណាច់អតីតភាពការងារដែលស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន១៥(ដប់ប្រាំ)ថ្ងៃ ក្នុង១(មួយ)ឆ្នាំ។ ប្រាក់បំណាច់នេះ ត្រូវបើកជូនកម្មករនិយោជិត៖*

- *ចំនួន៧,៥ (ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែមិថុនា នៃឆ្នាំនីមួយៗ និង*

- *ចំនួន៧,៥ (ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ...។*

យោងតាមប្រការ ២ នៃប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ខាងលើ និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិត ដែលកំពុងបម្រើការងារនូវប្រាក់បំណាច់អតីតភាពការងារចំនួន៧,៥ (ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែមិថុនា នៃឆ្នាំនីមួយៗ និង ចំនួន៧,៥ (ប្រាំពីរកន្លះ)ថ្ងៃ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ។ ផ្អែកតាមអង្គហេតុខាងលើ និយោជកបានបើកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី១ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិតរួចហើយ ប៉ុន្តែ និយោជកពុំបានបើកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិត សម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ នោះទេ ដោយសារមានការផ្ទុះឡើងនៃវីរុសកូរ៉ូណា ហើយអ្នកបញ្ជាទិញជំពាក់ប្រាក់ និងផ្អាកការបញ្ជាទិញ។

ពាក់ព័ន្ធនឹងការលើកឡើងរបស់និយោជកនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មិនមានបញ្ញត្តិណាមួយនៃច្បាប់និងប្រកាសទាក់ទងនឹងវិស័យការងារអនុញ្ញាតឱ្យនិយោជកពន្យារពេលបើកប្រាក់បំណាច់អតីតភាពជូនកម្មករនិយោជិតឡើយ។

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០។ យ៉ាងណាមិញ កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់នេះ គឺនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកបើកប្រាក់ប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិត នៅថ្ងៃដែលសេចក្តីបង្គាប់អាជ្ញាកណ្តាលនេះ ចូលជាស្ថាពរ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

- បង្គាប់ឱ្យនិយោជកបើកប្រាក់ឈ្នួលសម្រាប់ខែធ្នូ ឆ្នាំ២០១៩ ដែលនៅសល់ ជូនកម្មករនិយោជិតនៅថ្ងៃដែលសេចក្តីបង្គាប់អាជ្ញាកណ្តាលនេះ ចូលជាស្ថាពរ។

**ចំណុចវិវាទទី ២ ៖**

- បង្គាប់ឱ្យនិយោជកបើកប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិត នៅថ្ងៃដែលសេចក្តីបង្គាប់អាជ្ញាកណ្តាលនេះ ចូលជាស្ថាពរ។

**ចំណុចវិវាទទី ៣ ៖**

- បង្គាប់ឱ្យនិយោជកបើកប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆមាសទី២ នៃឆ្នាំ២០១៩ ជូនកម្មករនិយោជិត នៅថ្ងៃដែលសេចក្តីបង្គាប់អាជ្ញាកណ្តាលនេះ ចូលជាស្ថាពរ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ ប្រសិនបើមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **សេខ ឡូចហ៊ីន**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ស៊ីន គីមស៊ាន**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លៈ**

ហត្ថលេខា ៖ ------------------------------